# សន្ទរកថាបើករបស់ប្រធានក្រុមការងារវិស័យអប់រំ

# ក្នុងសន្និបាតអប់រំ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤

**Anne Lemaistre**

**តំណាងយូណេស្កូ ប្រចាំប្រទេសកម្ពុជា**

**ប្រធានក្រុមការងារវិស័យអប់រំ (ESWG)**

ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី

ឯកឧត្តម បណ្ឌិត **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ ភ្ញៀវកិត្តិយស

សហការីមកពីក្រុមការងារវិស័យអប់រំ លោកស្រី អស់លោក ជាទីមេត្រី

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមនៅក្នុងសន្និបាតអប់រំប្រចាំឆ្នាំ ២០១៤ តាងនាមឱ្យក្រុមការងារវិស័យអប់រំ (ESWG)។ ខ្ញុំសូមចែករំលែកនូវការឆ្លុះបញ្ចាំងមួយចំនួនដូចខាងក្រោមនេះ ក្នុងគោលបំណងបន្តពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នា ក្នុងការលើកកម្ពស់ការអប់រំ ការបង្រៀន និងរៀន សម្រាប់អ្នកសិក្សារៀនសូត្រគ្រប់រូប នៅក្នុងប្រទេសកម្ពុជា។

ក្រុមការងារវិស័យអប់រំ សូមសម្តែងនូវការអបអរសាទរជូនចំពោះឯកឧត្តមរដ្ឋមន្ត្រី ថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងអប់រំ យុវជន និងកីឡា និងលេខាធិការដ្ឋានរៀបចំសន្និបាតអប់រំ ដែលបានត្រៀម និងរៀបចំសន្និបាតនេះឱ្យលេចចេញជារូបរាងឡើង។ យើងក៏សូមថ្លែងអំណរគុណផងដែរចំពោះការចូលរួមយ៉ាងសកម្ម ពីសំណាក់នាយកដ្ឋានជំនាញទាំងអស់របស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាមន្ទីរអប់រំ យុវជន និង កីឡា រាជធានីខេត្តទាំងអស់ ដែលបានរៀបចំសន្និបាតអប់រំថ្នាក់ខេត្ត សម្រាប់ត្រៀមរៀបចំសន្និបាតអប់រំនៅថ្នាក់ជាតិនេះ។

ជារៀងរាល់ឆ្នាំ សន្និបាតនេះមានការចូលរួមពីគ្រប់តួអង្គសំខាន់ៗទាំងអស់ នៅក្នុងវិស័យអប់រំ និងបណ្តុះបណ្តាល ដើម្បីធ្វើការបូកសរុបលទ្ធផលការងារនៅក្នុងឆ្នាំកន្លងទៅ ធ្វើការអបអរសាទរនូវជោគជ័យ ដែលសម្រេចបាន ក៏ដូចជាធ្វើការកំណត់ពីយុទ្ធសាស្ត្រ និងសកម្មភាព សម្រាប់ឆ្នាំបន្ទាប់ខាងមុខ ក្នុងគោលបំណងលើកកម្ពស់ការផ្តល់នូវឱកាសទទួលបានការអប់រំ ដល់អ្នកសិក្សានៅក្នុងប្រទេស

កម្ពុជា។ សន្និបាតឆ្នាំនេះ រៀបចំឡើង ចំពេលនៃការចាប់ផ្ដើមអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ ដែលជាការបោះជំហានមួយទៀត ដើម្បីឈានទៅសម្រេចគោលបំណងអភិវឌ្ឍន៍ របស់រាជរដ្ឋាភិបាល ដែលចង់ក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០។

ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ជាទីមេត្រី !

យើងទាំងអស់គ្នាសុទ្ធតែបានដឹងយ៉ាងច្បាស់ពីសារៈសំខាន់នៃការអប់រំ។ សូមអនុញ្ញាតឱ្យខ្ញុំ ចែករំលែកនូវឧទាហរណ៍មួយចំនួនតូច ដកស្រង់ចេញពីរបាយការណ៍ពិនិត្យតាមដានជាសកល ២០១៣/១៤ របស់យូណេស្កូ ដែលត្រូវបានប្រកាសផ្សព្វផ្សាយ នៅក្នុងប្រទេសកម្ពុជា (សូមយក សេចក្តីសង្ខេបឯកសារនេះ ជាភាសាខ្មែរ) ដោយឯកឧត្តមរដ្ឋមន្ត្រី កាលពីថ្ងៃទី ៦ ខែ មីនា កន្លងទៅថ្មីៗ នេះ។ នៅក្នុងប្រទេសវៀតណាម កុមារ ដែលមានម្តាយរៀនបានមធ្យមសិក្សាបឋមភូមិ ទំនងជាមាន បញ្ហាក្រិន តិចជាងកុមារ ដែលម្តាយមិនបានទទួលការអប់រំ ចំនួន ៦៧%។ នៅតំបន់ជនបទក្នុង ប្រទេសឥណ្ឌូនេស៊ី ការទទួលបានការអប់រំបន្ថែមបានមួយឆ្នាំ កាត់បន្ថយឱកាសធ្លាក់ចូលទៅក្នុងភាព ក្រីក្រវិញ បាន ២៥%។

ខណៈពេលដែលប្រទេសកម្ពុជាខិតខំសម្រេចគោលដៅរបស់ខ្លួន ក្នុងការក្លាយជាប្រទេសដែល មានចំណូលមធ្យម នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ គេចាំបាច់ត្រូវតែធ្វើការពិចារណាលើ យុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់។ ប្រទេសកម្ពុជា ដែលមាន ចំណូលមធ្យម ដែលយើងទាំងអស់គ្នា នៅថ្ងៃនេះ ចង់សម្រេចឱ្យបាននៅក្នុងឆ្នាំ ២០៣០ ទាមទារឱ្យ មានមូលធនមនុស្ស ដែលទទួលបានការអប់រំ ការបណ្តុះបណ្តាល និងជំនាញ។ យើងទាំងអស់គ្នាគួរ ចង់ចាំថា មនុស្សដែលមានវ័យ ២០ ឆ្នាំ នៅឆ្នាំ ២០៣០ គឺជាកុមារដែលមានអាយុ ៤ ឆ្នាំ នាពេលនេះ ហើយជាពេលដែលពួកគេជិតចាប់ផ្តើមការអប់រំ នៅក្នុងវដ្តជីវិតរបស់ពួកគេ។ ដូច្នេះ យើងចាំបាច់ត្រូវតែ ចាប់ផ្តើមវិនិយោគឱ្យបានគ្រប់គ្រាន់លើការអប់រំ ពីពេលនេះទៅ ដើម្បីធានាឱ្យមានមូលដ្ឋានគ្រឹះរឹងមាំ តាមរយៈការគាំពារ និងអប់រំកុមារតូច ឱកាសរៀនសូត្រ និងបណ្តុះបណ្តាលប្រកបដោយគុណភាពល្អ ដែលបំពាក់បំប៉នដល់កុមារកម្ពុជាគ្រប់រូប រាប់បញ្ចូលទាំងកុមារពិការផង និងកុមារមកពីជនជាតិ ភាគតិចផង នូវជំនាញបច្ចេកទេស ជំនាញបុគ្គល និងជំនាញសង្គម ដើម្បីធ្វើការងារ និងរស់នៅជាមួយ គ្នា ក្នុងសង្គមសកលមួយ ដែលផ្សារភ្ជាប់ទំនាក់ទំនង និងពឹងអាស្រ័យលើគ្នាទៅវិញទៅមក។

ក្រុមការងារវិស័យអប់រំ មានសេចក្តីសោមនស្សរីករាយ សូមសម្តែងនូវការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងធ្វើការកែទម្រង់ និងការពិគ្រោះយោបល់ជាមួយគ្នាជាចំហ ជាពិសេស នៅក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ ពាក់ព័ន្ធនឹងកាលានុវត្តភាព និងបញ្ហាប្រឈមនានា ដែលមាននៅក្នុងការងារអប់រំ និងបណ្តុះបណ្តាល នៅក្នុងប្រទេសកម្ពុជា។ ក្រុមការងារវិស័យអប់រំ មានសេចក្តីសោមនស្សរីករាយ ដែលបានកត់សម្គាល់ឃើញថា រាជរដ្ឋាភិបាលបានអនុវត្តវិធានការជាជំហាន ដើម្បីផ្លាស់ប្តូរនិន្នាការនៃការថយចុះការវិភាជន៍ថវិកា មកឱ្យក្រសួងអប់រំ យុវជន និងកីឡា។ ការវិវឌ្ឍជាវិជ្ជមាន និងគាប់ប្រសើរមួយទៀត គឺការធានាឱ្យគ្រូទទួលបានបៀវត្សរបស់ខ្លួនទាន់ពេលវេលា និងតាមរយៈប្រព័ន្ធធនាគារ។ បើទោះបីជាពេលនេះ វាឆាប់ពេកក្នុងការធ្វើការវិនិច្ឆ័យក៏ដោយ ការវិវឌ្ឍបែបនេះ ជាការពិតនឹងនាំឱ្យមានផលវិជ្ជមានមកលើទឹកចិត្ត និងការប្រកបការងារប្រកបដោយវិជ្ជាជីវៈរបស់គ្រូ។

ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ជាទីមេត្រី

ខ្ញុំសូមអនុញ្ញាតចែករំលែកជាមួយឯកឧត្តម លោកជំទាវ លោកស្រី អស់លោក នូវចំណុចសំខាន់ៗមួយចំនួនចេញពីកិច្ចពិគ្រោះយោបល់ខ្លះៗ ដែលយើងមានកន្លងមក វឌ្ឍនភាពសំខាន់ៗដែលសម្រេចបាន ក៏ដូចជាបញ្ហាប្រឈម ដែលយើងចាំបាច់ត្រូវធ្វើការដោះស្រាយ ៖

- ចំណុចដំបូង និងសំខាន់ជាងគេបំផុត គឺការបង្ហើយបញ្ចប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ក្រោមការដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការផ្តោតការយកចិត្តទុកដាក់លើ "គុណភាព រួមជាមួយនឹងសមធម៌"។ ជាលទ្ធផល ប្រទេសកម្ពុជាទទួលបានជោគជ័យ នៅក្នុងការដាក់ពាក្យសុំ និងទទួលបានថវិកា ៣៨,៥ លានដុល្លារ ពីភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) ដែលក្រសួងនឹងចាប់ផ្តើមអនុវត្ត នៅខែនេះតែម្តង។ លើសពីនេះ ផែនការយុទ្ធសាស្ត្រវិស័យអប់រំនេះ ក៏ផ្តល់លទ្ធភាពឱ្យដៃគូអភិវឌ្ឍន៍ និងសមាជិកក្រុមការងារវិស័យអប់រំ អាចតម្រឹមការបន្តគាំទ្ររបស់ពួកគេមកដល់ប្រទេសកម្ពុជា ឱ្យមានទិសដៅស្របគ្នាផងដែរ។

- ទី ២ យើងបានរៀបចំប្រកបដោយជោគជ័យនូវអង្គវិប្បសនារួមគ្នា កាលពីចុងខែ មករា។ ទន្ទឹមនឹងការពិនិត្យឡើងវិញលើវឌ្ឍនភាពដែលសម្រេចបាន អង្គវិប្បសនានេះក៏បានកំណត់នូវវិធានការ ដែលចាំបាច់ត្រូវលើកយកមកធ្វើការពិចារណា សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំផងដែរ ដូចជា រចនាសម្ព័ន្ធសម្រាប់ការអនុវត្ត ការពិនិត្យតាមដាន និងការគ្រប់គ្រង

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ការបន្តការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) នៅក្នុងវិស័យអប់រំ កម្មវិធីសិក្សា ការអប់រំកម្រិតឧត្តមសិក្សា ការអភិវឌ្ឍគ្រូ និងអាហារូបករណ៍ ជាពិសេស ដោយផ្តោតគោលដៅលើសិស្សមធ្យមសិក្សា។ ការអនុវត្តវិធានការទាំងនេះពិតជានាំឱ្យមានផលវិជ្ជមានយូរអង្វែងមកលើ "គុណភាព រួមជាមួយនឹងសមធម៌" ជាពិសេស វិធានការទាំងនេះនឹងអាចដោះស្រាយនូវបញ្ហាប្រឈមពាក់ព័ន្ធជាមួយនឹងការរៀនត្រួតថ្នាក់ និងការបោះបង់ចោលការសិក្សា នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដែលបន្តអូសបន្លាយរហូតមកដល់ពេលនេះ។ ដើម្បីធានាឱ្យមានការពិនិត្យតាមដានលើវិធានការទាំងនេះប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវតែមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធ្វើការបង្កើនគុណភាពទិន្នន័យ និងពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ។

- ទី ៣ នៅក្រោមក្របខ័ណ្ឌក្រុមការងារបច្ចេកទេសចម្រុះ យើងបានឯកភាពគ្នាផ្តោតការយកចិត្តទុកដាក់លើការបង្កើនអត្រាបញ្ចប់ការសិក្សាថ្នាក់មូលដ្ឋាន ដែលជាផលសម្រេចមួយ ដែលត្រូវសម្រេចឱ្យបាននៅក្នុងរយៈពេល ៥ ឆ្នាំទៀត ជាមួយនឹងការបង្កើនចំនួនសិស្សចុះឈ្មោះចូលរៀន និងកាត់បន្ថយចំនួនសិស្សបោះបង់ចោលការសិក្សា នៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ស្របពេលដែលប្រទេសកម្ពុជានឹងចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន មិនដល់មួយឆ្នាំទៀតផងនោះ ការបណ្តុះបណ្តាលមូលដ្ឋាន ក៏ដូចជាការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នឹងក្លាយជាអាទិភាពលើអាទិភាពនានា សម្រាប់ប្រទេសកម្ពុជា និងរាជរដ្ឋាភិបាល។ នេះមានន័យថា ជាការធានាយ៉ាងណា ឱ្យអ្នកបានចុះឈ្មោះចូលរៀនហើយ នឹងមិនបោះបង់ចោលការសិក្សា ហើយពួកគេនឹងរៀនបានចប់ចុង ចប់ដើម។ ហើយអ្នកដែលមិនអាចរៀនចប់ចុងចប់ដើមបាន នឹងមានឱកាសទទួលបានការអប់រំជាលើកទី ២ តាមរយៈកម្មវិធីអភិវឌ្ឍន៍ជំនាញក្រៅប្រព័ន្ធ ជាមួយនឹងយន្តការសមមូលច្បាស់លាស់។ ក្នុងន័យនេះ ការអនុវត្តក្របខ័ណ្ឌវឌ្ឍិជាតិ ដែលទើបទទួលបានការអនុម័តកាលពីពេលថ្មីៗនេះ មានសារៈសំខាន់យ៉ាងខ្លាំង។

- ទី ៤ គឺភាពចាំបាច់ ដើម្បីធ្វើការពិនិត្យតាមដានលទ្ធផលសិក្សា សំដៅធានាឱ្យប្រាកដថាការសិក្សារៀនសូត្រពិតជាមានប្រាកដមែន។ របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ ២០១៣/១៤ ដែលចេញផ្សាយដោយយូណេស្កូ បង្ហាញថា មានសិស្សម្នាក់ ក្នុងចំណោមបួននាក់ នៅក្នុងប្រទេសក្រីក្រ មិនចេះអានឡើយ សូម្បីតែមួយប្រយោគ បើទោះបីជាពួកគេបានចំណាយពេល ៤ ឆ្នាំ នៅក្នុងសាលារៀនយ៉ាងណាក៏ដោយ។ បញ្ហានេះកំពុង

បង្កើតនូវវិបត្តិនៃការរៀនសូត្រ ដែលធ្វើឱ្យរដ្ឋាភិបាលនានាខាតបង់ថវិកា ១២៩ ពាន់លានុដល្លារ ក្នុងមួយឆ្នាំ ស្មើនឹងប្រមាណជា ១០ ភាគរយ នៃចំណាយលើការអប់រំកម្រិតបឋមសិក្សា។ យើងខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលការពិនិត្យតាមដានលើការវាយតម្លៃការសិក្សា សម្រាប់ថ្នាក់ទី ៣ ទី ៦ និងទី ៨ ក្លាយជាផ្នែកមួយនៃសូចនាករចាំបាច់សំខាន់ៗ ក្រោមក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រវិស័យអប់រំនេះ ហើយយើងខ្ញុំរំពឹងថា នឹងសហការជាមួយនឹងក្រសួង និងដៃគូនានា ក្នុងការបង្កើតប្រមូលភស្តុតាងបង្ហាញពីការរៀនសូត្រ និងយកភស្តុតាងច្បាស់លាស់ទាំងនេះ ទៅប្រើប្រាស់ក្នុងថ្នាក់រៀន ក៏ដូចជាយន្តការសម្រាប់រាយការណ៍ ពីផលសម្រេចនានា ដូចជាសន្និបាតអប់រំនេះ ជាដើម។

- ការផ្តោតការយកចិត្តទុកដាក់លើការរៀនសូត្រ គឺជាចំណុចទី ៥ ដែលខ្ញុំសូមលើកឡើងនាពេលនេះ។ ការរៀនសូត្រតម្រូវឱ្យមានគ្រូដែលមានសមត្ថភាព ទទួលបានការបណ្តុះបណ្តាល ការលើកទឹកចិត្ត និងការគាំទ្រវិជ្ជាជីវៈ។ យើងខ្ញុំសូមកោតសរសើរចំពោះសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ដើម្បីធានាយ៉ាងណាឱ្យគ្រូទទួលបានបៀវត្សទាន់ពេលវេលា តាមរយៈប្រព័ន្ធធនាគារ។ ដូចដែលបានលើកឡើងកន្លងមកហើយ មានបញ្ហាប្រឈមធ្ងន់ធ្ងរជុំវិញការជ្រើសរើស ការបង្កើនសមត្ថភាពរបស់គ្រូឱ្យបានច្រើននាក់ ការបែងចែក និងពង្រាយគ្រូ ការរក្សាគ្រូ ក៏ដូចជាការទាក់ទាញបេក្ខជនពូកែៗឱ្យចាប់យកអាជីពធ្វើជាគ្រូបង្រៀន។ របាយការណ៍ពិនិត្យតាមដានសកលរបស់ OECD និងយូណេស្កូ លើកឡើងថា ប្រសិនបើគេចង់ទាក់ទាញ និងរក្សាទុកអ្នកដែលមានសមត្ថភាព និងមានការលើកទឹកចិត្តឱ្យបន្តអាជីពបង្រៀន នោះបៀវត្ស និងប្រាក់លើកទឹកចិត្តសម្រាប់គ្រូ ត្រូវតែមានចំនួនគ្រប់គ្រាន់ ដើម្បីឱ្យគ្រួសារគ្រូមានជីវភាពលើបន្ទាត់នៃភាពក្រីក្រ (ឧទាហរណ៍ ប្រសិនបើគ្រូមានសមាជិកគ្រួសារចំនួន ៤ នាក់ ដើម្បីគាំទ្រ នោះគ្រូត្រូវការចំណូលយ៉ាងហោចណាស់ ១០ ដុល្លារ ក្នុងមួយថ្ងៃ ដើម្បីឱ្យគ្រួសារ របស់ខ្លួនស្ថិតនៅខាងលើបន្ទាត់ភាពក្រីក្រ ២ ដុល្លារ ក្នុងមួយថ្ងៃ សម្រាប់មនុស្សម្នាក់) ។

- ទី ៦ ការរៀនសូត្រក៏ទាមទារឱ្យមានការផ្គត់ផ្គង់សៀវភៅសិក្សា និងឯកសារសម្ភារៀនសូត្រក្នុងចំនួនគ្រប់គ្រាន់ផងដែរ។ ក្រុមការងារវិស័យអប់រំ រីករាយ ដែលបានឃើញមានការបង្កើនថវិកាសម្រាប់សៀវភៅសិក្សា។ ចំណុចនេះក៏ជាសូចនាករមួយ ក្នុងចំណោមសូចនាករពិនិត្យតាមដានរួមគ្នានានា ហើយយើងខ្ញុំរំពឹងថានឹងសហការជាមួយក្រសួង ដើម្បីពិនិត្យតាមដានលើការបែងចែកសៀវភៅសិក្សានេះ ដើម្បីធានាយ៉ាងណាឱ្យអ្នកសិក្សាគ្រប់រូបអាចទទួលបានសៀវភៅសិក្សា

ទៅតាមអ្វី ដែលបានកំណត់។ លើសពីនេះ យើងខ្ញុំសង្ឃឹមថា ការផ្ដល់ថវិកាកែលំអសាលារៀន នឹងផ្ដល់លទ្ធភាពឱ្យសាលារៀនអាចទទួលបានឯកសារសម្ភាររៀនសូត្របន្ថែមទៀត ទៅតាមតម្រូវការរបស់ខ្លួន។

- ទី ៧ យើងខ្ញុំសូមសម្ដែងនូវការអបអរសាទរចំពោះក្រសួងអប់រំ យុវជន និងកីឡា ដែលបានបញ្ចប់ និងអនុម័តលើផែនការសកម្មភាពអក្ខរកម្មប្រចាំប្រទេស ដែលនឹងផ្ដល់លទ្ធភាពឱ្យមានការពង្រីកអន្តរាគមន៍អក្ខរកម្ម សំដៅបង្កលក្ខណៈឱ្យអនក្ខរជនប្រមាណជា ២ លាននាក់ នៅក្នុងប្រទេសនេះ អាចប្រើប្រាស់សិទ្ធិរបស់ពួកគេ ក្នុងការទទួលបានឱកាសអក្ខរកម្ម និងរៀនសូត្រនានា។ ការអនុវត្តផែនការសកម្មភាពនេះប្រកបដោយប្រសិទ្ធភាព ក៏ជាការចាំបាច់ផងដែរ ដើម្បីកុំឱ្យប្រទេសកម្ពុជាខកខានមិនបានសម្រេចគោលដៅអក្ខរកម្ម នៅក្នុងការអប់រំសម្រាប់ទាំងអស់គ្នា។

- ទី ៨ ក្រុមការងារវិស័យអប់រំ រីករាយ ដែលបានកត់សម្គាល់ឃើញសេចក្ដីព្រាងគោលនយោបាយសង្ខេបអំពីការអប់រំកម្រិតឧត្ដមសិក្សា និងសូមស្វាគមន៍ចំពោះគំនិតផ្ដួចផ្ដើមកំណែទម្រង់នានាដែលបានស្នើឡើង ដើម្បីលើកកម្ពស់អភិបាលកិច្ច និងការគ្រប់គ្រងអនុវិស័យឧត្ដមសិក្សានេះ។ បើតាមបទពិសោធន៍ និងការអនុវត្តល្អនៅកម្រិតសកល និងតំបន់ ចាំបាច់ត្រូវមានស្ថាប័នស្វយ័តដែលមានតួនាទីភារកិច្ចធ្វើការធានាគុណភាព និងបញ្ជាក់គុណភាព ជាមួយនឹងអ្នកឯកទេសដែលមានសមត្ថភាព និងទទួលបានការបណ្ដុះបណ្ដាលត្រឹមត្រូវ ដើម្បីសម្រេចឱ្យបាននូវលទ្ធផលដែលគេចង់បានចេញពីកំណែទម្រង់ទាំងនេះ។

- ទី ៩ ការងាររបស់យុវជន ការមិនផ្គូរផ្គងគ្នារវាងការរំពឹងទុក និងបំណងប្រាថ្នារបស់យុវវ័យជាមួយនឹងទីផ្សារការងារ នៅតែជាក្ដីបារម្ភមួយ។ ក្រុមការងារវិស័យអប់រំ មានចិត្តរីករាយ ដែលបានមើលឃើញការបង្កើនការសហការគ្នារវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅក្រោមក្របខ័ណ្ឌគុណវឌ្ឍិជាតិ (CQF) នៅក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ។ យើងខ្ញុំនឹងបង្កើតភាពជាដៃគូជាមួយនឹងរដ្ឋាភិបាល ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល រួមជាមួយនឹងវិស័យឯកជន ដើម្បីអនុវត្តក្របខ័ណ្ឌគុណវឌ្ឍិជាតិនេះ រួមជាមួយនឹងយន្តការនានា ដើម្បីទាក់ទាញសិស្សានុសិស្សក្មេងៗ ដែលបោះបង់ចោលការសិក្សាពីប្រព័ន្ធអប់រំក្នុងប្រព័ន្ធ ឱ្យមកចូលរួម ក្នុងកម្មវិធីអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ។

- ទី ១០ ក្រុមការងារវិស័យអប់រំ សូមសម្តែងនូវការអបអរសាទរចំពោះរាជរដ្ឋាភិបាល ដែលបានបង្កើនថវិកាអប់រំ នៅក្នុងឆ្នាំ ២០១៤ ហើយគ្រោងនឹងបន្តបង្កើនថវិកានេះ ចាប់ពីឆ្នាំ ២០១៥ តទៅ ជាពិសេស ការអនុវត្តថវិកាកម្មវិធីឱ្យបាន ១០០% នៅក្នុងឆ្នាំ ២០១៥។ ក្រុមការងារវិស័យអប់រំសូមលើកទឹកចិត្តឱ្យក្រសួងអប់រំ យុវជន និងកីឡា រៀបចំកម្មវិធីវិនិយោគរបស់ខ្លួនឱ្យបានមធ្យ័ត ដើម្បីសម្រេចនូវគោលបំណងគោលនយោបាយ ដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ដែលនាំឱ្យមានការភ្ជាប់ទំនាក់ទំនងច្បាស់លាស់រវាងថវិកា និងគោលនយោបាយ។ ដើម្បីឱ្យការអនុវត្តថវិកាកាន់តែមានភាពល្អប្រសើរមួយកម្រិតទៀត ក្រុមការងារវិស័យអប់រំសូម លើកទឹកចិត្តឱ្យមានការបន្តខិតខំប្រឹងប្រែងជុំវិញកិច្ចការសំខាន់ៗចំនួន ៣ ៖ ១) កែលំអវិធាន និង នីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្តល់នូវភាពបត់បែន និងស្វ័យភាពដល់សាលារៀន ក្នុងការប្រើប្រាស់ថវិកាដំណើរការសាលារៀនប្រកបដោយប្រសិទ្ធភាព ២) បង្កើនប្រសិទ្ធភាពនៃការអនុវត្តថវិកា តាមរយៈការកែលំអការងារសវនកម្មផ្ទៃក្នុង និងដំណើរការលទ្ធកម្ម និង ៣) រៀបចំការពិនិត្យតាមដានថវិកា ប្រចាំត្រីមាស ដើម្បីឱ្យមានការកំណត់ និងដោះស្រាយឱ្យបានទាន់ពេលវេលា នូវបញ្ហានានា ដែលអាចបន្ទុចបង្អាក់មិនឱ្យមានការចំណាយថវិកាឱ្យបាន ១០០%។

- ទី ១១ ក្រុមការងារវិស័យអប់រំ សូមស្វាគមន៍នូវការបំពេញការងារយ៉ាងច្រើនកន្លងមករបស់ក្រសួង ជុំវិញកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ជាមួយនឹងការរៀបចំបញ្ជីវិភាគមុខងារ និងការពិនិត្យឡើងវិញលើមុខងារ ដែលជិតបញ្ចប់ទៅហើយនោះ ការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព និងគុណភាពនៃសេវាអប់រំ សម្រាប់អ្នកសិក្សាទាំងអស់។ បទពិសោធន៍ ដែលទទួលបានពីការបន្តអនុវត្តការងារមត្តេយ្យសិក្សាសហគមន៍ ក្រោមការគ្រប់គ្រង របស់ក្រុមប្រឹក្សាឃុំ នឹងផ្តល់នូវមេរៀនដ៏មានតម្លៃ សម្រាប់រៀបចំផែនការ និងអនុវត្តការផ្ទេរមុខងារបន្ថែមទៀត។

- ចុងក្រោយ ក្រុមការងារវិស័យអប់រំ ទទួលស្គាល់ពីភាពចាំបាច់ ដើម្បីបន្តពង្រឹងសមត្ថភាព ក្នុងការអនុវត្តកំណែទម្រង់ដែលគ្រោងទុកនេះ រួមជាមួយនឹងផែនការអនុវិស័យនានា ក្រោមផែនការយុទ្ធសាស្ត្រវិស័យអប់រំនេះ ប្រកបដោយភាពស័ក្តិសិទ្ធិ។ យើងខ្ញុំជឿជាក់ថា ជាមួយនឹងការគាំទ្របច្ចេកទេសពីសមាជិកក្រុមការងារវិស័យអប់រំ រួមជាមួយនឹងមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍

សមត្ថភាព ក្រសួងនឹងអាចទទួលបាននូវសមត្ថភាពស្ថាប័ន និងបច្ចេកទេសចាំបាច់នានា សម្រាប់អនុវត្តកំណែទម្រង់នេះ ក៏ដូចជាពិនិត្យតាមដានលើការអនុវត្តកំណែទម្រង់នេះប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក ជាទីមេត្រី !

យើងខ្ញុំមានទំនុកចិត្តថា បទបង្ហាញ ការពិភាក្សា និងការពិគ្រោះយោបល់ នៅក្នុងរយៈពេល ៣ ថ្ងៃ ខាងមុខនេះ នឹងបង្កើតបាននូវអនុសាសន៍ជាក់លាក់ សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ នេះ។ រួមគ្នាជាមួយនឹងសហការីមកពីក្រុមការងារវិស័យអប់រំ ខ្ញុំរំពឹងថានឹងមានការចូលរួមយ៉ាងសកម្មពីអ្នកចូលរួមទាំងអស់ នៅក្នុងការពិភាក្សាក្រុម ដើម្បីផ្តល់នូវធាតុចូលប្រកបដោយអត្ថន័យសម្រាប់ឆ្នាំខាងមុខ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំបន្ទាប់ ដែលកំពុងត្រូវបានព្រាងឡើង។ យើងខ្ញុំរំពឹងថា ការពិភាក្សាក្រុមនឹងមានលើសពីការទាញចេញជាសេចក្តីសន្និដ្ឋានទូទៅ ប៉ុន្តែលើកនូវដំណោះស្រាយជាក់លាក់ ចំពោះបញ្ហាប្រឈម ដែលបានកំណត់រកឃើញកន្លងមក។

តាងនាមតំណាងឱ្យក្រុមការងារវិស័យអប់រំ ជាថ្មីម្តងទៀត ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះស្ម័គ្រចិត្ត និងអំណរអរគុណជូនចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដែលបានផ្តល់ការគាំទ្រដល់ការអភិវឌ្ឍមូលធនមនុស្ស ដើម្បីធានាបាននូវការអភិវឌ្ឍដើម្បីទាំងអស់គ្នា ប្រកបដោយចីរភាពសម្រាប់ប្រទេសកម្ពុជា។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តមរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួង នាយកដ្ឋាន និងស្ថាប័នជំនាញ ក៏ដូចជាមន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត ចំពោះការសហការភាពជាដៃគូ និងកិច្ចពិគ្រោះយោបល់ជាមួយគ្នាកន្លងមក។ ខ្ញុំសូមគូសបញ្ជាក់សារជាថ្មីអំពីការបន្តផ្តល់ការគាំទ្រពីសំណាក់ក្រុមការងារវិស័យអប់រំ ជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងការធ្វើកំណែទម្រង់ ក៏ដូចជាកែលំអការងារអប់រំទាំងអស់ ដើម្បីឈានទៅសម្រេចចក្ខុវិស័យ គោលដៅ និង គោលបំណងរបស់ក្រសួង ក្រោមការដឹកនាំប្រកបដោយការប្តេជ្ញាចិត្តខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រី បណ្ឌិត ហង់ ជួនណារ៉ុន។

ខ្ញុំសូមជូនពរឱ្យការពិភាក្សាមានភាពរស់រវើក និងជូនពរឱ្យអង្គសន្និបាតទាំងមូលដំណើរការទៅប្រកបដោយជោគជ័យ។

សូមថ្លែងអំណរគុណ !